មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ ✓

បានយកសេចក្តីដំណាលជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៣៩ អនក្រ.តស

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្តាបនាជាតិ

ជូន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្តាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងដំបូលព្រះវិហារ ឧបដ្ឋានសាលា របង រោងទទួលភ្ញៀវ សាលាពុទ្ធិកបឋមសិក្សា តំនូរ សាលារៀន អណ្តូងទឹក និងបង្គន់អនាម័យ នៅវត្តបល្ល័ង្កជា ឃុំចន្ត្រី ស្រុកមេសរហែក ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសស្តាបនាជាតិ :

-លោក **សំ សារ៉ែត** ប្រធានការិ.ស្រាវជ្រាវនៃអាជ្ញាធរអប្សារា ថវិកា ៤៣.៥០០ ដុល្លារ

ខ.មេដាសង្ឃរាក់ស្តាបនាជាតិ :

១-អ្នកស្រី **ពាន គីមអ៊ុម** សប្បុរសជនខ្មែរស់នៅសហរដ្ឋអាមេរិក ថវិកា ៦០០០ ដុល្លារ

២-អ្នកស្រី **នុត គីមនារី** សប្បុរសជនខ្មែរស់នៅសហរដ្ឋអាមេរិក ថវិកា ៥០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨១៧ អន.ក្រ.តត

អនុក្រឹត្យ
ស្តីពីការដូនមេដាយសហមេត្រី

១១៥៧៥១១

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ ចិបឌិន្ន** ជូនលោក **Chinkolal Thangsing** ជាប្រធានអង្គការ **AIDS Health Foundation** ដែលបានខិតខំយកចិត្តទុកដាក់រកជំនួយឧបត្ថម្ភ និងគាំទ្រសកម្មភាពព្យាបាលអ្នកជំងឺមេរោគអេដស៍ អ្នកជំងឺអេដស៍ រួមទាំងការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ចំនួន ១១ កន្លែង នៅទីក្រុង និងខេត្ត ចំនួន០៩ ទៀត ដូចជា ខេត្តកំពង់ធំ កំពត ស្ទឹងត្រែង កណ្តាល ស្វាយរៀង ព្រៃវែង តាកែវ ពោធិ៍សាត់ និង ឧត្តរមានជ័យ ដោយប្រើប្រាស់ថវិកាជំនួយឥតសំណង ចំនួន ១.១៩៥.៣៤០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៩ ឆ្នាំ ២០០៨

ស្នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤១៣ អនក្រ.៩៩

អនុក្រឹត្យ
ស្តីពីការដួងមេដាយស្ថាបនាជាតិ
ឧទ្ធរណ៍

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវេជ្ជបណ្ឌិត **លង់ ចាន់ស្មី** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា ព្រះពុទ្ធបដិមា បល្ល័ង្កព្រះ និងឧបត្ថម្ភស៊ីម៉ង់ត៍ ដែក ប្រគេនព្រះសង្ឃ នៅ *វត្តវេឡុរតនាឫស្សីកែវ "ហៅវត្តដើមជ្រៃ"* ស្ថិតនៅក្នុងឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ សរុបចំនួន ១៣.៦០០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧១៤ អស(ក.ត)

អនុក្រឹត្យ
ស្តីពីការដូនមេដាយស្ថាបនាជាតិ
ឧ៥០៨ឧ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ០៣ រូប ដែលមានស្នាព្រះហស្តល្អ និងបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងកុដិ នៅវត្តទេពខនារាម ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយថ្នាក់ស្ថាបនាជាតិ :

១-លោក	**សំ សុន**	នៅរដ្ឋកាលីហ្វ័ញ្ញា	ថវិកាចំនួន ៦.៥០០ ដុល្លារ
២-អ្នកស្រី	**គីម តាព**	នៅរដ្ឋកាលីហ្វ័ញ្ញា	ថវិកាចំនួន ៥.៥០០ ដុល្លារ

ខ-មេដាយសិរីឆ្លស្ថាបនាជាតិ :

-ព្រះតេជគុណ **ឃុន សំហេង** ចៅអធិការវត្តទេពខនារាម មានស្នាព្រះបាស្តល្អក្នុងការចលនាពុទ្ធបរិស័ទ កសាងសមិទ្ធផលជាប្រយោជន៍ដល់សង្គមជាតិ និងព្រះពុទ្ធសាសនា ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥១៥ អនក្រ.៨៨

អនុក្រឹត្យ
ស្តីពីការប្រគល់តួនាទីភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ក្រសួងព័ត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២ រូប របស់ក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖
១_លោក **អ៊ុយ ចុនថី** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
២_លោក **ជឹម សោភា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
ជំនួសឯកឧត្តម **អ៊ីវ ផល្លី** ដែលត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៧ ៦ ក.ស/ក.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្តាបនាជាតិ

ច.ប.ស.

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្តាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន ១២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ បណ្ណាល័យ សាលាឆាន់ សាលាបុណ្យ កុដិ របងខ្លោងទ្វារ និងសមិទ្ធផលនានា នៅវត្តកោះរកា ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ព្រមទាំងបានជួយកសាងសាលាកិត្តិយស កុដិឈើ ព្រះវិហារ និងសមិទ្ធផលមួយចំនួនទៀត នៅវត្តសុវណ្ណារ៉ាម ឃុំច្រកមៀស ស្រុកស្វាយទាប ខេត្តស្វាយរៀង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្តាបនាជាតិ :

១-លោក	ស្រ៊ី	លីម	សប្បុរសជន	ថវិកា ចំនួន ១២.៩២៥ ដុល្លារ
២-លោក	អ៊ាន	ឈេង់ន	សប្បុរសជន	ថវិកា ចំនួន ១២.៥៥៥ ដុល្លារ
៣-លោក	ជា	សាវ៉ឿន	សប្បុរសជន	ថវិកា ចំនួន ១០.៨៥៣ ដុល្លារ
៤-លោក	ណេង	សារុន	សប្បុរសជន	ថវិកា ចំនួន ១០.៥០០ ដុល្លារ
៥-ព្រះតេជគុណ	ឆ្លួច	ថៃ		បច្ចុយ ចំនួន ១០.៣០៥ ដុល្លារ

ខ-មេដាយប្លាក់ស្តាបនាជាតិ :

១-លោក	ស្រ៊ី	ឈេង់ន	សប្បុរសជន	ថវិកា ចំនួន ៨.៧០៣ ដុល្លារ
២-លោក	ខាត់	ជីម	សប្បុរសជន	ថវិកា ចំនួន ៨.៦៨៣ ដុល្លារ
៣-លោក	លឹង	គី	សប្បុរសជន	ថវិកា ចំនួន ៨.៥១២ ដុល្លារ
៤-លោក	មុត	គ្រឿន	សប្បុរសជន	ថវិកា ចំនួន ៨.៤៨១ ដុល្លារ
៥-លោក	ពុត	កែវ	សប្បុរសជន	ថវិកា ចំនួន ៨.៣៥៤ ដុល្លារ

គ.មេដាយសិរីឆ្នស្តាបនាជាតិ :

១-លោក	**រីម**	**រាត**	សប្បុរសជន	ថវិកា ចំនួន ៣.៩៥៥ ដុល្លារ
២-លោក	**សៀន**	**សេង**	សប្បុរសជន	ថវិកា ចំនួន ៣.៣៧៦ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលខេត្តកំពង់ធំ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៨

ក.ន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨១៧អន.ក.៥៨

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

១១៦៧ឆ្នាំ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ចំនួន ៣៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យទេសចរណ៍ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ សេនា :

១-លោក	ពេញ	ពន្លក	អគ្គនាយករងទេសចរណ៍
២-លោក	សុខ	តុងហាប់	ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
៣-លោក	គង់	សូលីដា	នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
៤-លោក	អ៊ុក	សុខា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
៥-លោក	ឈឹម	ឥណ្ឌថា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
៦-លោក	ម៉ៅ	សុចិត្រា	អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
៧-លោកស្រី	ឈូក	ឈូឥន្ទ្រ	អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
៨-លោក	ឡឹក	យ៉ែម	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៩-លោកស្រី	ហួ	សុជារី	អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
១០-លោក	ញ៉ឹម	សុខ	ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់
១១-ឯកឧត្តម	ជិន	ឡឹម	ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១២-លោក	ចិន	សាម៉ន	ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

១៣-លោក	ប៉ុច	យ៉ែន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម
១៤-លោក	ភុយ	សខ	ប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរាប
១៥-លោក	ហ៊ុន	សារឿន	ប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
១៦-លោក	ជុន	ម៉ែន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៧-លោក	ណែម	ស៊ីឡន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពត
១៨-លោក	ប៊ុន	ប្បេវ	ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង
១៩-លោក	សេង	លីថេង	ប្រធានមន្ទីរទេសចរណ៍ក្រុងប៉ៃលិន

ខ-មេដាយសុវត្ថារាជ្ឋាភិរមេ្យឫច្ឆិ :

១-លោក	គង់	សុភារក្ស	ប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍
២-លោក	ចន	សំជីន	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
៣-លោក	កើត	ពុទ្ធថារី	អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍
៤-លោក	ឆ្លាក់	ចំន្ទតារា	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
៥-លោក	យិន	ស៊ុំថេង	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ
៦-លោក	ស្រ៊ី	សារឿន	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
៧-លោក	សំ	ឆុន្ធា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
៨-លោក	កែវ	ទាសនា	នាយការិ.សរុបនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
៩-លោក	មាស	ប៉ូលីកា	នាយការិ.នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
១០-លោក	រ៉ុម	សុិនឈារិទ្ធ	នាយការិ.នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
១១-លោកស្រី	សឹម	សុភាព	នាយរងការិ.នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
១២-លោក	ស៊ុំវ	រុន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
១៣-លោក	ឈឿ	ម៉ុងដែន	ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ
១៤-លោក	រេង	ឆាំក់	ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង
១៥-លោក	ត្រា	នុតស៊ាន	ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគីរី
១៦-លោក	ឆាយ	ខ្វឹន	ប្រធានមន្ទីរទេសចរណ៍ក្រុងកែប
១៧-លោក	តន់	ប៊ុនរឿង	ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤១៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការដូនមេដាយការងារ
១១២៧១១

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ចំនួន ៨៥ រូប ដែលមានស្នាដៃល្អក្នុងការបំពេញការកិច្ច លើវិស័យទេសចរណ៍ ដូចមានរាយនាម ខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោកបណ្ឌិត	សួន	រ៉ានី	ប្រធានក្រុមអ្នកច្បាប់
២-លោកស្រី	តឹក	សុតី	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ
៣-លោក	យិន	ណាត	នាយការិ. GMS នាយកដ្ឋានផែនការអភិវឌ្ឍន៍
៤-លោក	សួស	សារ៉ន	នាយការិ.នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៥-លោក	ជា	សុខុម	នាយការិ.នាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល
៦-លោក	នាង	វិបុល	នាយការិ.នាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល
៧-លោក	ឆិត្យ	វ៉ែត	នាយការិ.នាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល
៨-លោក	អ៊ុន	ឥន្ទសារី	នាយការិ.នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៩-លោក	សោម	ប៊ុនណាត	នាយការិ.អង្គការអន្តរជាតិ ន.សហ.ការអន្តរជាតិនិងអាស៊ាន
១០-លោក	ឆឺង	ប៊ុន្ធី	នាយការិ.ស្ថានតំណាងន.សិក្សាទីផ្សារនិងផ្សព្វផ្សាយ
១១-លោក	ជួង	សុខត្ថារ៉ា	នាយការិ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
១២-លោក	ឆឺម	សុខណ្ឌ	នាយរងការិ.នាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ

១៣-លោក	ឆួន	សេដា	នាយរងការិ.រដ្ឋបាលរបៀបន.រដ្ឋបាលនិងកិច្ចការទូទៅ
១៤-លោក	ជា	ចាន់ហោ	នាយរងការិ.តំកល់ឯកសារន.រដ្ឋបាលនិងកិច្ចការទូទៅ
១៥-លោកស្រី	ឯម	ង៉ាន់សារ៉ាត្ថ	នាយរងការិ.តំកល់ឯកសារន.រដ្ឋបាលនិងកិច្ចការទូទៅ
១៦-លោក	ហាស់	ស៊ីន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១៧-លោក	ឆាំង	ប៊ុនហាន	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១៨-លោក	កែត	សុផល	មន្ត្រីមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

ខ.មេដាយបន្ទាក់ការងារ :

១-លោក	ឆុត	ងារក្ស	អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍
២-លោក	ស៊ូ	គីមព្រឿន្នា	អនុប្រធាននាយកដ្ឋានក្រុមអ្នកច្បាប់
៣-លោកស្រី	ប៉ូច	ទរលក្ខណ៍	នាយរងការិ.អង្គការអន្តរជាតិន.សហ.ការអន្តរជាតិនិងអាស៊ាន
៤-លោក	គីម	ទីរៈ	នាយរងការិ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
៥-លោក	ហ៊ាង	មិត	នាយរងការិ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
៦-លោកស្រី	កង	មណី	នាយរងការិ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
៧-លោក	អ៊ឹម	ទិមល	នាយរងការិ.នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៨-លោក	អ៊ុន	ឈុនលី	នាយរងការិ.នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
៩-លោក	ឡោ	ចូរ៉ា	មន្ត្រីនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
១០-លោកស្រី	ធីម	ស៊ីម៉ុន	មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
១១-លោក	ណែម	ស៊ីវឌ្ឍនា	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១២-លោក	ពៅ	ង៉ារ៉ូ	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១៣-លោកស្រី	ហ៊ុច	ចំឆុឃួ	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១៤-លោក	ឡេង	ពីឆ្នុត	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១៥-លោក	ស្រ៊ី	ម៉ារ៉ាឌី	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១៦-លោកស្រី	យ៉ាន់	រ៉ាវី	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១៧-លោក	គិត	ចំឆើ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
១៨-លោកស្រី	ហួត	ស៊ុនន	មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៩-លោក	ឆ្យុច	ជារិទ្ធ	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
២០-លោក	ម៉ា	សុណារិន	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
២១-លោក	ហួត	សាខ័ន	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
២២-លោកស្រី	គូ	តាស់	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
២៣-លោក	ពុន	យុទ្ធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
២៤-លោក	ង៉ែត	ចំឆតារា	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តតាកែវ
២៥-លោកស្រី	ង៉ែ	សុវត្ថិធី	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តតាកែវ
២៦-លោក	សូ	ជាឆ្លី	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពត
២៧-លោក	ញ៉ាន់	ប៊ុនណារិទ្ធ	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពត
២៨-លោក	ឃី	ឃីម	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកោះកុង
២៩-លោក	សុិន	ជា	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តក្រចេះ
៣០-លោក	សុខ	ឈាវ	ប្រធានការិ.មន្ទីរទេសចរណ៍ក្រុងកែប
៣១-លោក	ត្រោក	គីមមាន	អនុប្រធានការិ.មន្ទីរទេសចរណ៍រាជធានីភ្នំពេញ

គ.មេដាយសិរីឆ្នាំការងារ :

១-លោកស្រី	ហូឡា	សុតានី	នាយរងការិ.នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
២-លោកស្រី	តូច	ទីរយ៉ា	នាយរងការិ.នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៣-លោកស្រី	ជីង	សៅគន្ធន៍អ៊ីរ	នាយរងការិ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
៤-លោក	យ៉ីម	ប៊ុនឆ្យើន	មន្ត្រីនាយកដ្ឋានអប់រំនិងបណ្តុះបណ្តាល
៥-លោកស្រី	ហួតនន់	សុខាវណ្ណណែត	មន្ត្រីនាយកដ្ឋានអប់រំនិងបណ្តុះបណ្តាល
៦-លោក	ហ៊ុល	សីលា	មន្ត្រីនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
៧-លោកស្រី	ឃួន	សាំងរដ្ឋា	មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៨-លោក	សិត	ឆាយ	មន្ត្រីអធិការដ្ឋាន
៩-លោក	ហម	វណ្ណៈ	មន្ត្រីអធិការដ្ឋាន
១០-លោកស្រី	យន្ត	សុគន្ធា	មន្ត្រីអធិការដ្ឋាន
១១-លោក	យ៉ីម	ចេតនា	មន្ត្រីអធិការដ្ឋាន
១២-លោក	ឌួង	សុលីណា	ជំនួយការឯកឧត្តមអនុរដ្ឋលេខាធិការ
១៣-លោកស្រី	អ៊ុំ	និមល	មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៤-លោកស្រី	សូរ្យ	សុវណ្ណកញ្ញារ៉ា	មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៥-លោក	ឆេត	សុខុម	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១៦-លោក	ស៊ឹម	សារ៉ុំ	មន្ត្រីនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១៧-លោក	ហ៊ាង	រិទ្ធ	មន្ត្រីនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
១៨-លោកស្រី	សន	សំអ៊ឿន	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
១៩-លោកស្រី	ប៉ែន	សុភា	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
២០-លោកស្រី	កែត	ឈាងអួន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២១-លោក	សំ	ហ៊ឹម	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២២-លោក	ឃូ	សុខា	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២៣-លោក	ប៉ុល	ស៊ីមហេង	មន្ត្រីមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២៤-លោកស្រី	ហួន	សុខអួន	មន្ត្រីមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២៥-លោកស្រី	គង់	ឡេងរ៉ែន	មន្ត្រីមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២៦-លោកស្រី	ពេជ្រ	ចំល្លី	មន្ត្រីមន្ទីរទេសចរណ៍ខេត្តព្រះវិហារ
២៧-លោកស្រី	សៀ	គីមញ៉ាន	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តពោធិសាត់
២៨-លោកស្រី	ប៉ែន	សុភា	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តពោធិសាត់
២៩-លោកស្រី	ម៉ី	សារឹម	ប្រធានការិ.មន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី
៣០-លោក	វ៉ែត	សៀន	មន្ត្រីមន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី
៣១-លោក	សៅ	ណុប	មន្ត្រីមន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី
៣២-លោកស្រី	ប៉ុល	អ៊ុំជែន	មន្ត្រីមន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី

៣៣-លោក	ឈាង	ឆាយ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៣៤-លោកស្រី	គង់	ឥណ្ណៈពិសី	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពង់ចាម
៣៥-លោក	យ៉ាង	ប៊ុនិន	មន្ត្រីមន្ទីរទេសចរណ៍ខេត្តតាកែវ
៣៦-លោកស្រី	សាយ	ពិសី	មន្ត្រីមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

មាត្រា២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ស្នាយុត្តរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០២១៩ - ២០៨ - ៥៤

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំ រ ច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ចំនួន ០២ នាក់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ត្រី **ម៉ាត់ ឈួរ** អត្តលេខ ០១៩៣ ពីប្រធានអធិការដ្ឋាននគរបាល ទៅជាទីប្រឹក្សាក្រសួងមហាផ្ទៃ ។

២- លោកឧត្តមសេនីយ៍ត្រី **សួស សុខុន** អត្តលេខ ០២១៩១ អនុប្រធានអធិការដ្ឋាននគរបាល ទៅជាប្រធានអធិការដ្ឋាននគរបាល ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ទីស្នាក់ការឧត្តមនាយករដ្ឋមន្ត្រី*
- *ទីស្នាក់ការឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ* ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៨៣០- ២៨៩-តស

អនុក្រឹត្យ
ស្តីពី
ការកែសំរួលតារាងកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំ រ ច

មាត្រា ១ : ត្រូវបានកែសំរួលភារកិច្ចឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ឹម សុផល** អគ្គលេខ ០០៤៣ បច្ចុប្បន្នអគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន មកជាអគ្គស្នងការរងនគរបាលជាតិ ។

មាត្រា ២ : ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ចំនួន ០២ នាក់ ដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **សេង ជីវន្ត** អគ្គលេខ ០១០២ បច្ចុប្បន្នប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ទៅជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

២-លោកឧត្តមសេនីយ៍ត្រី **ឆ្លាត ភាណារ៉ា** អគ្គលេខ ០១៦៥ បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ទៅជាប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី
រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:.១២៧អ.ន.ស/០៨

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦ /នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ពតិមាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន
- បានឃើញអនុក្រឹត្យ លេខ ៧១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការកែសំរួលអគ្គនាយកដ្ឋាន រដ្ឋបាលសោតទស្សន៍ជាអគ្គនាយកដ្ឋានរដ្ឋបាល និងបរិវារភ្នាក់ងារ និងអគ្គនាយកដ្ឋានពតិមាន និងសោតទស្សន៍របស់ក្រសួងពតិមាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការជ្នាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងពតិមាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ជិន ឈាត** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងពតិមាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពតិមាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមាន ចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ជូនមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

11/5/2008 PSSD

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៨៧..អនក្រ-៨៥

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **អ៊ឹង ម៉ូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ ពីរូប ជាជំនួយការឯកឧត្តម **អ៊ឹង ម៉ូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចមានរាយនាមខាងក្រោម :

១- លោក **អ៊ុក ឥន្ទ្រា** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២- លោកស្រី **អ៊ុក នីឌ្យា** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ..១៧.. ខែ ..វិច្ឆិកា.. ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំង និងការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

ស ម្រ ច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការក្រសួងផែនការដូចមានរាយនាមខាងក្រោម ÷

១-លោក **ថេង បញ្ញាឆន** វរមន្ត្រីថ្នាក់លេខ ១០ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ជំនួសឯកឧត្តម **នុត ច័ន្ទសុខា** ។

២-លោក **ជា ចាន់ថុំ** វរមន្ត្រីថ្នាក់លេខ ៨ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ជំនួសលោកជំទាវ **ប៊ាង សៀកលី** ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការរបស់ក្រសួងផែនការដូចមានរាយនាមខាងក្រោម ÷

១-លោកស្រី **ជុំ ពុទ្ធានី** អនុមន្ត្រីថ្នាក់លេខ ៨ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការសង្គមកិច្ច នៃអគ្គនាយកដ្ឋានផែនការជំនួស លោក **ជា ចាន់ថុំ** ។

២-លោក **ឈុប កនណារុឌ្ឍ** អនុមន្ត្រីថ្នាក់លេខ ១០ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការវិនិយោគ នៃអគ្គនាយកដ្ឋានផែនការជំនួស **លោក ថេង បញ្ញាឆន** ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជាឱ្យអាក្រក់ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨៩៨៩

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី

នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ដែលនឹងប្រព្រឹត្តិធ្វើចាប់ពីថ្ងៃទី១៩-២១ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅខេត្តសៀមរាប ដែលមានសមាសភាពដូចរាយនាមខាងក្រោម :

១.	ឯកឧត្តម **បម ប្រសិទ្ធ**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២.	ឯកឧត្តម **ស៊ុយ សែម**	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	អនុប្រធាន

៣. ឯកឧត្តម **អ៊ុក រ៉ាប៊ុន**	រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៤. ឯកឧត្តម **តោគ សុវណ្ណរិទ្ធ**	រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៥. ឯកឧត្តម **អ៊ុច ឫទ្ធិ**	រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៦. ឯកឧត្តម **ជាន សូរស័ក្តិ**	រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	សមាជិក
៧. ឯ.ឧ ឧត្តមសេនីយ៍ឯក **ឃូ ស៊ុនឈុន**	អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
៨. ឯ.ឧ ឧត្តមសេនីយ៍ឯក **សៅ សុខា**	មេបញ្ជាការកងរាជអាវុធហត្ថ ក្រសួងការពារជាតិ	សមាជិក
៩. ឯកឧត្តម **ស៊ូ តារិទ្ធ**	អភិបាលខេត្តសៀមរាប	សមាជិក
១០. ឯកឧត្តម **សុខ សុតន្ត្រា**	អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម	សមាជិក

ប្រការ ២.-

គណៈកម្មការរៀបចំសន្ធិសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច មានភារកិច្ចដូចតទៅ :

- រៀបចំកម្មវិធីសន្ធិសីទ និងពិធីការឱ្យបានសមស្រប
- រៀបចំគំរោងចំណាយសម្រាប់រៀបចំសន្ធិសីទខាងលើ ឱ្យស្របតាមគោលការណ៍ហិរញ្ញវត្ថុ
- សម្របសម្រួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកចូលរួមសន្ធិសីទ ក្នុងឱកាសស្នាក់នៅ និងទស្សនកិច្ចនៅតាមកន្លែងនានា ឱ្យបានល្អ
- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ
- សម្របសម្រួល និងរៀបចំដំណើរទស្សនាចរជូនគណៈប្រតិភូតាមកម្មវិធីដែលបានគ្រោងទុក
- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីការរៀបចំសន្ធិសីទ។

ប្រការ ៣.-

ប្រធានគណៈកម្មការរៀបចំសន្ធិសីទ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង ស្ថាប័ន រាជធានី ខេត្តពាក់ព័ន្ធនានា ឱ្យមកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

ប្រការ ៤.-

ប្រធានគណៈកម្មការរៀបចំសន្ធិសីទ អាចបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ។

ប្រការ ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អភិបាលខេត្តស្ទឹងមានជ័យ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៣.ស.ស.ស

សេចក្តីសំរេច

ស្តីពី

ការផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាអភិបាលជាតិគ្រប់គ្រងតំរោងជំនួយ ផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១០៥/ ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងអនុសារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- យោងអនុសារណៈ ស្តីពីការរៀបចំចាត់ចែងទាក់ទងនឹងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧
- យោងសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងតំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា

- យោងសេចក្តីសំរេចលេខ ៥៣ សសរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងតំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងសេចក្តីសំរេចលេខ ១០ សសរ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងតំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងតំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា។

សំរេច

ប្រការ១: ត្រូវបានតែងតាំងលោក **ឱរេល សយ** អភិបាលរងខេត្តបាត់ដំបង ជាសមាជិកក្រុមពិគ្រោះយោបល់នៃក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងតំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងជាជនបង្គោលសំរាប់ខេត្តបាត់ដំបង ជំនួសលោក **អ៊ុក ឥច្ឆ**។

ប្រការ២: រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្ជឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាបនាពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងសាមីខ្លួនដូនមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨

ចម្លងជូន:
-ក្រសួងព្រះបរមរាជវាំង
-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់សមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
-ដូចប្រការ១
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៥៩ សហវ.-ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាការិយាល័យនៃ នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្កើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.-

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងការកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

ប្រការ ២.-

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនបួន (០៤) ដូចខាងក្រោម ៖

- ការិយាល័យផែនការ និងគោលនយោបាយគយ
- ការិយាល័យបច្ចេកទេសគយ
- ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា
- ការិយាល័យកិច្ចការអន្តរជាតិ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមការកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

ប្រការ ៣.-

ការិយាល័យផែនការនិងគោលនយោបាយគយ មានមុខងារ និងការកិច្ចដូចតទៅ ៖

- លើកសំណើគោលនយោបាយសមស្របពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ និងចូលរួមធ្វើសេចក្តីព្រាងបទបញ្ញត្តិ និងកំណត់ផែនការពាក់ព័ន្ធនឹងការងារប្រមូលពន្ធ និងអាករគ្រប់ប្រភេទឲ្យបានសមស្របទៅតាមតំណាក់កាលនីមួយៗនៃការវិវត្តន៍គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋ។
- លើកឡើងនូវផែនការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សិក្សា និងវិភាគបណ្តាគោលនយោបាយសេដ្ឋកិច្ចនានា ពាក់ព័ន្ធនឹងគយ។
- ចូលរួមឃ្លាំមើល និងវាយតម្លៃការអនុវត្តន៍កិច្ចប្រតិបត្តិការគយ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ប្រការ ៤.-

ការិយាល័យបច្ចេកទេសគយ មានមុខងារ និងការកិច្ចដូចតទៅ ៖

- គ្រប់គ្រង កសាង និងតាមដានពិនិត្យការអនុវត្តន៍បទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងតារាងពន្ធគយ ការកំណត់តម្លៃគិតពន្ធគយ ឬអាករគយលើទំនិញនាំចេញ

នាំចូល ការវិវត្តនៃការកំណត់ដើមកំណើតទំនិញឲ្យបានទាន់ពេលវេលា និងស្របតាមការវិវត្តន៍នៃសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ។

- ស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីយោងតម្លៃគិតពន្ធ ឬអាករគយ លើទំនិញនាំចេញ នាំចូល តម្លៃរបិយប័ណ្ណ អត្រាប្តូរប្រាក់តាមការកំណត់របស់ច្បាប់ និងបទបញ្ជាត្តិជាធរមាន ព្រមទាំងចូលរួមត្រួតពិនិត្យ ផ្ទៀងផ្ទាត់មើលការអនុវត្តន៍នូវបណ្តាតារាង និងបញ្ជីទាំងនេះ។
- បំពេញតួនាទី ពិនិត្យ និងផ្តល់យោបល់លើការកំណត់តម្លៃគិតពន្ធ ឬអាករគយ ការកំណត់ដើមកំណើត និងការកំណត់ចំណាត់ថ្នាក់ទំនិញ និងចូលរួមផ្តល់យោបល់លើទិដ្ឋភាពបច្ចេកទេសគយពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ប្រការ ៥.-

ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា មានមុខងារ និងភារកិច្ចដូចតទៅ៖

- កសាងយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជា ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- រៀបចំបទបញ្ជាត្តិ និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា។
- រៀបចំគ្រប់គ្រងការស្រង់ប្រមូល និងរក្សាទិន្នន័យ និងស្ថិតិនៃការនាំចេញ នាំចូល។
- ប្រមូលផ្តុំទិន្នន័យទំនិញនាំចេញ នាំចូល ជាលក្ខណៈសង្ខេប ជាប្រចាំរាល់ដំណាច់ខែ ត្រីមាស ឆ្នាំនីមួយៗ។
- រៀបចំតភ្ជាប់បណ្តាញកុំព្យូទ័រនៅក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងគ្រប់គ្រងការប្រើប្រាស់ និងថែរក្សាបណ្តាញនេះ។
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល និងផ្នែកឯកជនក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើពាណិជ្ជកម្មអន្តរជាតិ ។
- ប្រមូលផ្តុំព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធនឹងកិច្ចការគយ និងរដ្ឋាករដល់អាជីវករ និងអតិថិជន ដោយប្រើប្រាស់គ្រប់មធ្យោបាយ រួមទាំងមធ្យោបាយអេឡិចត្រូនិចផងដែរ ។
- សហការជាមួយអង្គការតំបន់ និងអន្តរជាតិ ព្រមទាំងរដ្ឋបាលគយនៃប្រទេសផ្សេងទៀតក្នុងការផ្លាស់ប្តូរព័ត៌មាន ការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ប្រការ ៦.-

ការិយាល័យកិច្ចការអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅ៖

- *លើកឡើងនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជាក្នុងបរិបទសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។*
- *សិក្សា និងផ្តល់អនុសាសន៍ស្តីពីការចូលរួមប្រតិបត្តិការផ្នែកគយ នៅក្នុងអង្គការតំបន់ និងពិភពលោក ព្រមទាំងជម្រុញបង្កើនទំនាក់ទំនងទ្វេភាគី ជាមួយរដ្ឋបាលគយនៃប្រទេសផ្សេងៗ។*
- *តាមដាន និងសម្របសម្រួលការអនុវត្តន៍នូវកាលកំណត់នៃកិច្ចរបស់កម្ពុជា ពាក់ព័ន្ធនឹងកិច្ចការគយ ក្រោមកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី។*
- *វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍អំពីផលប៉ះពាល់ផ្សេងៗ ដែលអាចកើតមានឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីទាំងនោះ ជាពិសេសពាក់ព័ន្ធនឹងចំណូលពន្ធគយ។*
- *សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ។*
- *សហការជាមួយអង្គភាពពាក់ព័ន្ធនានា នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីស្រាវជ្រាវព័ត៌មាន ពាក់ព័ន្ធនឹងបទល្មើសគ្រប់ប្រភេទពីបណ្តាប្រភពក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងចូលរួមវិភាគ និងវាយតម្លៃហានិភ័យលើព័ត៌មានទាំងនេះ។*
- *គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។*
- *បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។*

មាត្រា ៧.-

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្វឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៨៩.ស.ហវ.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាការិយាល័យនៃ នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៦ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ*
- *បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើត នាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រ៉ូបន្ទ ស្ថិតក្រោម ការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការទូរការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.-

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យ នៃនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងការកិច្ចរបស់បណ្តាការិយាល័យទាំងនេះៗ

ប្រការ ២.-

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន កិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនពីរ (០២) ដូចខាងក្រោម ៖

- ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ
- ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋាន កិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមការកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់ៗ

ប្រការ ៣.-

ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ មានមុខងារ និងការកិច្ចដូចតទៅ ៖

- សហការស្រាវជ្រាវ និងផ្តល់យោបល់ ពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ
- ទទួលបន្ទុកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ និងការធ្វើវិសោធនកម្ម ឬការកែសម្រួលបទប្បញ្ញត្តិគយ ✓

- ទទួលបន្ទុកពិនិត្យ និងចូលរួមពិនិត្យសំណើសុំបង្កើតកណ្តាគារគយមានដែនកំណត់តំបន់រួចពន្ធ និងបណ្តាអាជីវកម្មដ្ឋានប្រហាក់ប្រហែល និងចាត់ចែង គ្រប់គ្រង ត្រួតពិនិត្យទីកន្លែង និងសេវាកម្មទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងកិច្ចសន្យាជាធរមាននានា
- ទទួលបន្ទុកគ្រប់គ្រងកំណត់ហេតុបទល្មើសគយ និងមានការកិច្ចសម្រុះសម្រួលបទល្មើសគយ និងវិវាទផ្សេងទៀត ដោយផ្តល់យោបល់សម្រាប់បម្រើឲ្យការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានា ជាក់ជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ពិនិត្យ និងសម្រេច ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- តម្កល់ឯកសារ និងបទប្បញ្ញត្តិច្បាប់ជាធរមាននានា និងណែនាំដល់គ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អំពីរបៀបគ្រប់គ្រង ថែទាំឯកសារទាំងនេះ
- ទទួលពិនិត្យ និងវាយតម្លៃនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជន និងបុគ្គលពាក់ព័ន្ធនានាក្នុងនាមជាអង្គភាពទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងគោលដៅរក្សាតុល្យភាពរវាងប្រសិទ្ធភាព នៃការអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីពាក់ព័ន្ធក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ប្រការ ៤.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ ត្រូវអនុវត្តតាមបញ្ញត្តិប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ និងមានមុខងារ និងការកិច្ចបន្ថែមដូចតទៅ ៖

- ទទួលបន្ទុកជាអង្គភាពគ្រប់គ្រងជើងសារគយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីពាក់ព័ន្ធក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ប្រការ ៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ភាគ ឈន់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសោធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ
  * ដើម្បីជូនជ្រាប *
- ជូចប្រការ ៦ *ដើម្បីអនុវត្ត*
- ឯកសារ - កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៣៥ សហវ-ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាគារិយាល័យនៃ
នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

*** ២០៨ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រួច

ប្រការ ១.-

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

ប្រការ ២.-

ត្រូវបានកំណត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួន ពីរ (០២) ដូចខាងក្រោម :

- ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ច ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

ប្រការ ៣.-

ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំ និងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយ និងរដ្ឋាករ។
- រៀបចំគ្រប់គ្រងស្ថិតិលើទិន្នន័យបុគ្គលិក និងតារាងព័ត៌មាន សកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយ និងរដ្ឋាករ។
- ចូលរួមរៀបចំការងារផ្លាស់ប្តូរ ផ្ទេរភារកិច្ច តម្លើងឋានៈ ឬបន្ថយឋានៈចំពោះមន្ត្រីរាជការគយ និងរដ្ឋាករ ក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- រៀបចំបៀវត្សន៍ ក្របខ័ណ្ឌ ប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ និងគ្រប់គ្រងគោលនយោបាយធានារ៉ាប់រងសង្គម និងរបបសំរាកលំហែ។
- គ្រប់គ្រងការចេញលិខិតឧទ្ទេសនាម ឬលិខិតបញ្ជាបេសកកម្មរបស់មន្ត្រីរាជការគយនិងរដ្ឋាករ។
- ចូលរួមរៀបចំគោលនយោបាយ លើកសរសើរ ផ្តល់កិត្តិយស ជាកវិន័យ ស្តីបន្ទោស ឬព្រមានដល់មន្ត្រីគយ និងរដ្ឋាករ ដោយផ្អែកតាមច្បាប់ និងបទបញ្ជាត្តិជាធរមាននានា។
- គ្រប់គ្រង និងចារចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- ចាត់ចែង និងសហការរៀបចំទិវាបុណ្យជាតិ និងអន្តរជាតិនានា និងពិធីចាំបាច់ផ្សេងៗក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងស្ថិតិ ការប្រើប្រាស់អាវុធរបស់អង្គភាព។
- ចាត់ចែង រៀបចំ និងត្រួតពិនិត្យនូវការគោរពវិន័យការងារ ការថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាទាំងមូល។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

ប្រការ ៤.-

ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ចដូចតទៅ :

- ចូលរួមលើកគម្រោងផែនការប្រមូលចំណូលពន្ធ អាករគ្រប់ប្រភេទ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងតាមដានរំលឹកអំពីការប្រតិបត្តិ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា នីតិវិធីនានា បំរើឱ្យការងារគណនេយ្យពន្ធគយ។
- គ្រប់គ្រងបញ្ជីស្នាមពាក់ព័ន្ធនឹងប្រាក់ពន្ធលើទំនិញនាំចេញ នាំចូល ប្រាក់ផាកពិន័យ ប្រាក់រង្វាន់ ប្រាក់បំណុល ប្រាក់បៀវត្សន៍ និងរាល់ចំណូលផ្សេងៗទៀតដែលមាន។
- គ្រប់គ្រងការងារហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជារួម ជាពិសេសតាមរយៈការប្រមូលផ្តុំតម្រូវការ និងធ្វើកម្មវិធីចំណាយរបស់អង្គភាពឱ្យបានទៀងទាត់ ដោយត្រូវគ្រប់គ្រងការធ្វើរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ និងធ្វើរបាយការណ៍សម្រេចទូទាត់ចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងការទិញ ការបែងចែកមធ្យោបាយ សម្ភារបរិក្ខារនានាសំរាប់បំពេញការងាររបស់អង្គភាព។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារ ធ្វើបញ្ជីសារពើភ័ណ្ឌ និងគ្រប់គ្រងការប្រើប្រាស់អាគារ ការរៀបចំជួសជុលផ្សេងៗរបស់អង្គភាព។
- តាមដាន រំលឹក ការគ្រប់គ្រងគណនីពិសេស។
- កាន់កាប់រាល់សាលាកប័ត្រ និងបញ្ជីគណនេយ្យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- បោះពុម្ពបង្គាន់ដៃពន្ធ ឯកសារបច្ចេកទេស បញ្ជីគណនេយ្យ ឯកសារផ្លូវការ តែមប្រឹលតាប់ត្រយានយន្ត និងឯកសារនានា ដែលទាក់ទងនឹងការងារគយ និងរដ្ឋាករ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

ប្រការ ៥.-

បទបញ្ជាត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត- ក្រុងដែលពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៣៤ ពណរ.នតក

ភ្នំពេញថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: ប្រុនស៍ ហស
	BRONZE HORSE Co.,Ltd
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 10428/07P ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក **សៅ សុទត្ថាសនា**
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: បូរី ស្បែងណាំ ភូមិខ្នារ ឃុំជ្រាវ ស្រុកស្បែមរាប ខេត្តស្បែមរាប
៥- កម្មវត្ថុអាជីវកម្ម	: -ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម ទិញ លក់ ដីធ្លី ផ្ទះសំបែង

-ទេសចរណ៍ : ទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារ័ណ អាបអ័ណទំនិញគ្រប់ប្រភេទ នាំចូល នាំចេញ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

- ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៥៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អ៊ឹម ស៊ុថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តស្ទឹងត្រាង
- មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រាង "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៣៧ ពណ.នតក

ភ្នំពេញថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណីរបស់ក្រុមហ៊ុន	: **ដឺ ខហ្វហ្គី មេកឃើរ**	
	THE COFFEE MAKER Co., Ltd.	
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 10424/07P ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៧	
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត	
២- អភិបាលក្រុមហ៊ុន	: លោក **ខៀវ ចេសេន**	ប្រធានក្រុមប្រឹក្សាភិបាល
	លោកស្រី PUNCHARAT RATANAWORASET	អភិបាល
	លោក **ជា សារិន**	អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល	
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ១០ E1 ផ្លូវលេខ ២៩៦ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។	
៥- កម្មវត្ថុអាជីវកម្ម	: -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត	
	-ពាណិជ្ជកម្ម : ទិញ លក់ ផ្ទាស់ប្តូរទំនិញ នីហារ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ នាំចូលនិងនាំចេញ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ	
	-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ	
	-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង	
	-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ	
	-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ	
	-បើកសាលារៀន	
	-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម	
	-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម	
	-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស	
	-សេវាផ្សាយពាណិជ្ជកម្ម	
	-បោះពុម្ពផ្សាយ	
	-ផលិតខ្សែភាពយន្ត វីដេអូ CD	

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៥៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម ស៊ុថន

បំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពតិមាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៤០ ពណ.នតក

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណីរបស់ក្រុមហ៊ុន	: **ប៊ី & ប៊ី អ៊ុនធើណេសិនណល**
	BE & BE INTERNATIONAL Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 10433/07P ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកិរិត
២- អភិបាលក្រុមហ៊ុន	: លោក **នីម ខារ៉ាសាន់** ប្រធានក្រុមប្រឹក្សាភិបាល
	លោកស្រី GOOSSENS BELINDA G.S.J.G អភិបាល
	លោក TRIGAUX BENOIT P.M.G អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ៤ A ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ
	នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
	-ការជួលងាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញ
	គ្រប់ប្រភេទ
	-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
	-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
	-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
	-បើកសាលារៀន
	-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
	-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
	-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
	-សេវាផ្សាយពាណិជ្ជកម្ម
	-បោះពុម្ពផ្សាយ
	-ផលិតខ្សែភាពយន្ត វីដេអូ CD
	-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញតាមប្រៃសណីយ៍

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហ៊ាម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៤១ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន **MANSARD INTERNATIONAL LIMITED (BVI)** និងត្រូវបានចុះបញ្ជីពាណិជ្ជកម្មនិងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **គ្រីអេធីវ អេនធើតេនមេន ខូ អិលធីឌី**

CREATIVE ENTERTAINMENT CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3989/07E ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **SCOTT SHAWN ANDRE** " ឥតីយជន "

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ជាន់ទី៥ នៃសណ្ឋាគារភ្នំពេញ លេខ ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : - សណ្ឋាគារ ភោជនីយដ្ឋាន និង មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យសំណង់
-សេវាកម្មកន្លែងលំហែកាយ និងកីឡា
-ពាណិជ្ជកម្ម : នាំចេញ នាំចូល
-សេវាកម្មទេសចរណ៍ និង រៀបចំការស្នាក់នៅសំរាប់ភ្ញៀវទេសចរ
-សេវាកម្មជំនាញទេព្រៃ ដែលមិនផ្ទុយនឹងសេវាកម្មដែលបានរៀបរាបខាងលើ
-អាជីវកម្មដែលមិនត្រូវបានហាមឃាត់ដោយច្បាប់កម្ពុជា ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ឧេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម-សុខន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៤៦ ពណ.នតក

ភ្នំពេញថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន **LAMGROVE INVESTMENT LIMITED (BVI)** និងត្រូវបានចុះបញ្ជី ពាណិជ្ជកម្មនិងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប្រ៊ីដ ឃែភីថល អ៊ុនវេសមេន ខូ អិលធីឌី**

BRIDGE CAPITAL INVESTMENT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3987/07E ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **SCOTT SHAWN ANDRE** " តតិយជន "

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ជាន់ទី៥ នៃសណ្ឋាគារភ្នំពេញ លេខ ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : - សណ្ឋាគារ ភោជនីយដ្ឋាន និង មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យសំណង់

-សេវាកម្មកន្លែងលំហែកាយ និងកីឡា

-ពាណិជ្ជកម្ម : នាំចេញ នាំចូល

-សេវាកម្មទេសចរណ៍ និង រៀបចំការស្នាក់នៅសំរាប់ភ្ញៀវទេសចរ

-សេវាកម្មដឹកជញ្ជូនដែលទាក់ទងនឹងសេវាកម្មដែលបានរៀបរាបខាងលើ

-អាជីវកម្មផ្សេងទៀតដែលមិនត្រូវបានហាមឃាត់ដោយច្បាប់កម្ពុជា ។

៦- ថិរវេលា : ៥៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ភីម សុខន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៤៦ ពណ.ឧតក

ភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

អនុសរណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	:	**អាត្លង់ទិក វើលដ៍**
		ATLANTIC WORLD Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	:	Co. 4003/07E ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	:	ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកិរិត
២- អភិបាលក្រុមហ៊ុន	:	លោក IMAHASHI TAKAYUKI ប្រធានក្រុមប្រឹក្សាភិបាល
		លោក **ខាន់ លី** អភិបាល
		លោក **ឡាង ខៀវ** អភិបាល
៣- ដើមទុនក្រុមហ៊ុន	:	ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	:	ផ្ទះលេខ ១៤៣ ផ្លូវលេខ ១៦០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម	:	-ពាណិជ្ជកម្ម : ទិញ លក់ ផ្គាស់ប្តូរទំនិញ នីហារ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ ឥវ៉ាចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងទូវជលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ ជលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាសំរួលទំនិញតាមផ្លូវទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ឧទ្ធសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម ស៊ុីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០៤៩/ ពណ.ឧតត

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	:	**អេអិមខេមវៀត អ៊ីមផត អិចផត**
		AMCAMVIET IMPORT EXPORT Co.,Ltd
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	:	Co. 3997/07E ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	:	សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	:	លោក JAMES HAROLD MCLAUGHLIN
៣- ដើមទុនក្រុមហ៊ុន	:	ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	:	ផ្ទះលេខ ២៧ ផ្លូវលេខ ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម	:	-ពាណិជ្ជកម្ម : ទិញ លក់ ផ្ទាស់ប្តូរទំនិញ ទីបារ័ណ អាបារ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ - ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកបរិរក្ខាវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាឃ្លាំង និងផ្ទុកភ្ជាយទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន